**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ១៧១ MOC / SM 2009

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការរៀបចំយុទ្ធសាស្ត្រសំរាប់ជំរុញវិស័យសូត្រនៅកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩១អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម

-យោងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពី គម្រោង រៀបចំយុទ្ធសាស្ត្រសំរាប់ជំរុញវិស័យសូត្រនៅកម្ពុជា

-យោងលើតំរូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ។

## សំរេច

**ប្រការ ១.-** ត្រូវបានបង្កើតគណៈកម្មការមួយឈ្មោះ "**គណៈកម្មការរៀបចំយុទ្ធសាស្ត្រសំរាប់ជំរុញវិស័យសូត្រនៅកម្ពុជា**" ។ គណៈកម្មការនេះស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម ហើយដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | ឯកឧត្តម | ឆាន់ សុវសំឬទ្ធិ | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២ | ឯកឧត្តម | ម៉ៅ ថូរ៉ា | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣ | លោកជំទាវ | ញៀម មរកត | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | អនុប្រធាន |
| ៤ | ឯកឧត្តម | ឡោ រស្មី | អគ្គលេខាធិការនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥ | លោក | ឌិច ស៊ីនី | អគ្គនាយករងនៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦ | លោក | ហួត សារឹម | អគ្គនាយកនៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧ | លោក | តឹប ឡើន | អគ្គនាយករងនៃក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ | សមាជិក |
| ៨ | លោក | ស៊ិន សុថា | ប្រធាននាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩ | លោក | អ៊ុច គីមយ៉ុន | ប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០ | លោក | ឈឹម សុធី | អនុប្រធាននាយកដ្ឋានសិល្បៈសូន្យរូប និង សិល្បៈសិប្បកម្ម | សមាជិក |
| ១១ | លោក | ស្រី សារឿន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ វប្បធម៌ | សមាជិក |
| ១២ | លោក | កែ មុន្នី | តំណាង សមាគមភូមិសូត្រខ្មែរ (KSV) | សមាជិក |
| ១៣ | លោក | ស៊ុំ គីមយ៉ុន | តំណាងសម្ព័ន្ធសិប្បកម្មកម្ពុជា (CCC) | សមាជិក |
| ១៤ | អ្នកស្រី | José WAHL | តំណាង Craft Network | សមាជិក |
| ១៥ | លោក | ម៉ែន ស៊ីនឿន | តំណាង សមាគមសិប្បករកម្ពុជា (AAC) | សមាជិក |
| ១៦ | អ្នកអង្គម្ចាស់ | ស៊ីសុវត្ថិ ភានុវង្ស | អ្នកសម្របសម្រួលគម្រោងសូត្រ PCU-ITC | លេខាធិការ |

**ប្រការ ២.- គណៈកម្មការនេះមានភារៈកិច្ចដូចតទៅ ៖**

-កំណត់យុទ្ធសាស្ត្រ និងលើកស្នើនូវវិធានការនានាគាំទ្រដល់ការអភិវឌ្ឍន៍វិស័យសូត្រនៅកម្ពុជា

-ផ្តល់ព័ត៌មានទីផ្សារ និងស្វែងរកទីផ្សារសម្រាប់ផលិតផលសូត្រកម្ពុជា

-ជួយលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ផលិតកម្មសូត្រកម្ពុជា

-សហការសម្របសម្រួលជាមួយអង្គភាពសម្របសម្រួលគម្រោងសូត្រ (PCU-ITC) និងអ្នកពាក់ព័ន្ធលើវិស័យសូត្រ ទាំងអស់ ដើម្បីឱ្យការអនុវត្តនូវយុទ្ធសាស្ត្រវិស័យសូត្រនៅកម្ពុជា មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងទទួលបានជោគជ័យ

-ធានាឱ្យមានការធ្វើផែនការបច្ចេកទេស និងថវិកាប្រចាំឆ្នាំជាក់ស្តែងពីអង្គភាពសម្របសម្រួលគម្រោងសូត្រ (PCU-ITC)

-ជួយសម្របសម្រួលដល់អង្គការ (ITC) និងអ្នកសម្របសម្រួលគម្រោង ក្នុងការស្វែងរកថវិកាបន្ថែមសំរាប់អនុវត្តន៍គំរោង

-ពិនិត្យ តាមដានការងារប្រតិបត្តិរបស់អង្គភាពសម្របសម្រួលគម្រោងសូត្រ (PCU-ITC)

-បង្កើតមគ្គុទេសក៍សំរាប់តាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ

-ជួយដោះស្រាយវិវាទ និងការលំបាកផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ

-បង្កើតលេខាធិការដ្ឋានរបស់គណៈកម្មការ

-រាយការណ៍ជាប្រចាំជូនក្រសួងពាណិជ្ជកម្ម និងចំលងជូនក្រសួង ស្ថាប័នពាក់ព័ន្ធលើលទ្ធផលការងារ ។

**ប្រការ ៣.- លេខាធិការដ្ឋាន**

-គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលដឹកនាំដោយលេខាធិការមួយរូប

-លេខាធិការដ្ឋានមានភារកិច្ចធ្វើការងារប្រចាំថ្ងៃ រៀបចំការប្រជុំផ្សេងៗ និងការងារសម្របសម្រួលនានា

-រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ រៀបចំសកម្មភាពជាក់ស្តែងជូនគណៈកម្មការ គ្រប់គ្រងថវិកា និងធ្វើការងារផ្សេងៗតាមការណែនាំរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៤.- របៀបរបបធ្វើការងាររបស់គណៈកម្មការ**

-នៅពេលអវត្តមានរបស់ប្រធាន អនុប្រធានត្រូវជំនួសដោយស្វ័យប្រវត្តិ

-គណៈកម្មការត្រូវជួបប្រជុំរាល់២ខែម្តង ឬច្រើនជាងនេះតាមការសំរេចរបស់ប្រធាន

-ក្នុងករណីដែលការសំរេចណាមួយតម្រូវឱ្យមានការបោះឆ្នោត សំឡេងត្រូវយកជាបានការគឺ លើសពីពាក់កណ្តាលនៃសមាជិកដែលមានវត្តមាននៅពេលបោះឆ្នោត

-ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមភាព ។

**ប្រការ ៥.-** គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្មលើលិខិតស្នាមផ្លូវការរបស់ខ្លួន ។

**ប្រការ ៦.-** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន:</u>**

- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងកិច្ចការនារី
- ដូចមានក្នុងប្រការ១ និងប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ